# ថ្នាំបង្ការ

## សម្រាប់អ្នកដែលមានផ្ទៃពោះ



ប្រសិនបើអ្នកមានផ្ទៃពោះ ថ្នាំបង្ការនានាអាចការពារទាំងអ្នក និងទារករបស់អ្នកពីជំងឺផ្សេងៗណាដែលអាចទប់ស្កាត់បាន។ ថ្នាំបង្ការទាំងឡាយបង្រៀនរាងកាយរបស់អ្នកឱ្យស្គាល់អំពីមេរោគជំងឺ (viruses) និងមេរោគរស់ (bacteria) ណាដែលបង្កគ្រោះថ្នាក់ ហើយផលិតអង់ទីក័រពិសេសដើម្បីធ្វើឱ្យអ្នក និងទារករបស់អ្នកនៅតែមានសុខភាពល្អ។ នៅពេលដែលអ្នកទទួលចាក់ថ្នាំបង្ការក្នុងអំឡុងពេលមានផ្ទៃពោះ អង់ទីក័ររបស់អ្នកមួយចំនួនគឺមានបញ្ជូនទៅដល់ទារករបស់អ្នកមុនពេលកើត។ អង់ទីក័រទាំងនេះផ្តល់ប្រព័ន្ធការពារប្រឆាំងនឹងជំងឺកម្រិតធ្ងន់ធ្ងរដល់ទារករបស់អ្នកក្នុងអំឡុងពេលពីរឬបីខែដំបូងនៃជីវិតរបស់ពួកគេ។



### ចំណុចទាំងនេះគឺជាអ្វីដែលអ្នកត្រូវការយល់ដឹង៖

- ថ្នាំបង្ការទាំងឡាយគឺមានសុវត្ថិភាពក្នុងអំឡុងពេលមានផ្ទៃពោះសម្រាប់អ្នកដែលមានផ្ទៃពោះ និងទារករបស់ពួកគេ ផងដែរ។
- ការចាក់ថ្នាំបង្ការក្នុងអំឡុងពេលមានផ្ទៃពោះគឺជាវិធីល្អបំផុតដើម្បីការពារទារកទើបនឹងកើតពីជំងឺកម្រិតធ្ងន់ធ្ងរ ជាពិសេសដោយសារតែពួកគេមិនអាចទទួលចាក់ថ្នាំបង្ការបាននៅឡើយ។

### ថ្នាំបង្ការទាំងឡាយដែលត្រូវការទទួលចាក់ក្នុងអំឡុងពេលមានផ្ទៃពោះ៖

**ថ្នាំបង្ការ Tdap៖**

- ទទួលចាក់ថ្នាំបង្ការ Tdap ក្នុងអំឡុងពេលសប្តាហ៍ទី 27 រហូតដល់សប្តាហ៍ទី 36 នៃ<u>ការមានផ្ទៃពោះម្តងៗ</u> ដើម្បីជួយការពារទារករបស់អ្នកពីជំងឺក្អកមាន់ (pertussis/whooping cough)។
- ជំងឺក្អកមាន់គឺមានកម្រិតធ្ងន់ធ្ងរជាពិសេសសម្រាប់ទារកទើបនឹងកើត ហើយអាចគំរាមកំហែងដល់ជីវិត ផងដែរ។

**ថ្នាំបង្ការជំងឺ COVID-19៖**

- ថ្នាំបង្ការជំងឺ COVID-19 គឺមានសុវត្ថិភាពក្នុងការទទួលចាក់នៅពេលណាក៏ដោយក្នុងអំឡុងពេលមានផ្ទៃពោះរបស់អ្នក។
- អ្នកដែលមានផ្ទៃពោះគឺកាន់តែទំនងជានឹងធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរដោយសារជំងឺ COVID-19 ប្រៀបធៀបទៅនឹងអ្នកដែលមិនមានផ្ទៃពោះ។
- ការទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 ដែលបានធ្វើឱ្យថ្មីឡើងវិញផ្តល់ប្រព័ន្ធការពារដល់ទារកទើបនឹងកើតរបស់អ្នកក្នុងអំឡុងពេលពីរឬបីខែដំបូងនៃជីវិតរបស់ពួកគេ រហូតដល់ពេលដែលទារករបស់អ្នកអាចទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 របស់ពួកគេផ្ទាល់បាននៅអាយុ 6 ខែ។
- អ្នកដែលមានផ្ទៃពោះគួរតែរង់ចាំរយៈពេលយ៉ាងហោចណាស់ 2 ខែចាប់តាំងពីបានចាក់ថ្នាំបង្ការជំងឺ COVID-19 ដូសចុងក្រោយបង្អស់ប្រភេទណាមួយក៏ដោយរបស់ពួកគេ មុនពេលទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 ដែលបានធ្វើឱ្យថ្មីឡើងវិញនេះចំនួនមួយដូស។

**ថ្នាំបង្ការសម្រាប់ RSV៖**

- អ្នកដែលមានផ្ទៃពោះអាចទទួលចាក់ថ្នាំបង្ការសម្រាប់មេរោគប្រភេទ syncytial ដែលឆ្លងតាមផ្លូវដង្ហើមរបស់មនុស្ស (respiratory syncytial virus/RSV) ចំនួនមួយដូស ក្នុងអំឡុងពេលសប្តាហ៍ទី 32 រហូតដល់សប្តាហ៍ទី 36 នៃការមានផ្ទៃពោះ និងក្នុងអំឡុងពេលខែកញ្ញា រហូតដល់ខែមករា ដើម្បីការពារទារកទើបនឹងកើតរបស់ពួកគេប្រឆាំងនឹង RSV។ RSV បង្កឱ្យមានជំងឺរលាកផ្លូវដង្ហើមតូចៗ (bronchiolitis) និងជំងឺរលាកសួត (pneumonia) ចំពោះទារកតូចៗ។
- ដើម្បីទប់ស្កាត់ជំងឺកម្រិតធ្ងន់ធ្ងរដែលបង្កឡើងដោយ RSV មិនឱ្យកើតចំពោះទារក មានការណែនាំឱ្យមានការចាក់ថ្នាំបង្ការសម្រាប់ RSV ដល់ម្តាយ (maternal RSV vaccination) ឬការចាក់ថ្នាំប្រភេទ nirsevimab ដល់ទារក ក្រោយពេលកើតភ្លាមៗ ក្នុងអំឡុងពេលរដូវកាលមាន RSV ច្រើន។ ទារកភាគច្រើននឹងត្រូវការប្រព័ន្ធការពារតែមួយបែបប៉ុណ្ណោះ។

COUNTY OF LOS ANGELES
Public Health

# ថ្នាំបង្ការ

## សម្រាប់អ្នកដែលមានផ្ទៃពោះ



**ថ្នាំបង្ការជំងឺគ្រុនផ្ដាសាយធំ (Flu)៖**

- ថ្នាំបង្ការជំងឺគ្រុនផ្ដាសាយធំគឺមានសុវត្ថិភាពក្នុងការទទួលចាក់នៅពេលណាក៏ដោយក្នុងអំឡុងពេលមានផ្ទៃពោះរបស់អ្នក។
- អ្នកដែលមានផ្ទៃពោះគឺកាន់តែទំនងជានឹងធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរដោយសារជំងឺគ្រុនផ្ដាសាយធំ។
- ទារកដែលមានអាយុក្មេងជាង 6 ខែប្រឈមនឹងហានិភ័យខ្ពស់បំផុតក្នុងការត្រូវសម្រាកព្យាបាលនៅមន្ទីរពេទ្យដោយសារជំងឺគ្រុនផ្ដាសាយធំ ប្រៀបធៀបទៅនឹងកុមារដែលមានអាយុផ្សេងទៀត។
- ការធ្វើឱ្យថ្នាំបង្ការជំងឺគ្រុនផ្ដាសាយធំនៅតែគ្រប់លក្ខណៈនិងទាន់ពេលវេលាផ្ដល់ប្រព័ន្ធការពារដល់អ្នក និងទារកទើបនឹងកើតរបស់អ្នកក្នុងអំឡុងពេលពីរឬបីខែដំបូងនៃជីវិតរបស់ពួកគេ រហូតដល់ពេលដែលទារករបស់អ្នកអាចទទួលចាក់ថ្នាំបង្ការជំងឺគ្រុនផ្ដាសាយធំរបស់ពួកគេផ្ទាល់បាន។

**ថ្នាំបង្ការជំងឺរលាកថ្លើមប្រភេទ B (Hepatitis B)៖**

- អ្នកដែលមានផ្ទៃពោះ ហើយដែលមិនបានចាក់ថ្នាំបង្ការប្រឆាំងនឹងជំងឺរលាកថ្លើមប្រភេទ B ពីពេលកន្លងមកទេនោះ គួរតែទទួលចាក់ថ្នាំបង្ការជំងឺរលាកថ្លើមប្រភេទ B ក្នុងអំឡុងពេលមានផ្ទៃពោះ ដើម្បីការពារពួកគេផ្ទាល់ និងទារករបស់ពួកគេពីការឆ្លងមេរោគ និងជំងឺផ្សេងៗដែលបង្កឡើងដោយមេរោគជំងឺរលាកថ្លើមប្រភេទ B នេះ។ ជំងឺរលាកថ្លើមប្រភេទ B អាចបណ្ដាលឱ្យមានការខូចខាតរយៈពេលវែងទៅដល់ថ្លើមបាន។

## ថ្នាំបង្ការទាំងឡាយដែលទារកត្រូវការទទួលចាក់នៅពេលទើបនឹងកើត៖

**ថ្នាំបង្ការជំងឺរលាកថ្លើមប្រភេទ B (Hepatitis B)៖**

- ទារកទើបនឹងកើតរបស់អ្នកគួរតែទទួលចាក់ថ្នាំបង្ការជំងឺរលាកថ្លើមប្រភេទ B ដូសដំបូងក្នុងអំឡុងពេល 24 ម៉ោងក្រោយពេលកើត ដើម្បីការពារពួកគេពីការឆ្លងមេរោគជំងឺរលាកថ្លើមប្រភេទ B។

**ការចាក់ថ្នាំសម្រាប់ RSV (ប្រភេទ Nirsevimab)៖**

- ប្រសិនបើអ្នកមិនបានទទួលចាក់ថ្នាំបង្ការសម្រាប់ RSV ក្នុងអំឡុងពេលមានផ្ទៃពោះទេ ឬប្រសិនបើកូនរបស់អ្នកកើតក្នុងអំឡុងពេល 14 ថ្ងៃនៃការទទួលចាក់ថ្នាំបង្ការសម្រាប់ RSV នោះ ទារកទើបនឹងកើតរបស់អ្នកគួរតែទទួលចាក់ថ្នាំប្រភេទ nirsevimab ចំនួនមួយដូស មុនពេលឬក្នុងអំឡុងពេលរដូវកាលមាន RSV ច្រើន ដើម្បីការពារពួកគេពីជំងឺកម្រិតធ្ងន់ធ្ងរ។ RSV គឺជាមូលហេតុបង្កកើតមានទូទៅបំផុតដែលបណ្ដាលឱ្យទារកទើបនឹងកើតរបស់អ្នកត្រូវសម្រាកព្យាបាលនៅមន្ទីរពេទ្យ។

ទារករបស់អ្នកក៏នឹងទទួលថ្នាំបន្តក់ប្រឆាំងនឹងការឆ្លងមេរោគទៅក្នុងភ្នែក ថ្នាំចាក់វីតាមីន K ចំនួនមួយម្ជុល និងការធ្វើតេស្តឈាមសាមញ្ញមួយសម្រាប់ការត្រួតពិនិត្យទារកទើបនឹងកើតផងដែរ។ ប្រសិនបើអ្នកមានសំណួរផ្សេងៗ សូមសាកសួរទៅកាន់អ្នកផ្ដល់សេវាកម្មថែទាំនៅពេលមានគភ៌របស់អ្នក នៅតាមការណាត់នាពេលបន្ទាប់។



### មជ្ឈមណ្ឌលផ្ដល់ព័ត៌មានរបស់នាយកដ្ឋានសុខភាពសាធារណៈ (Public Health Call Center)

សម្រាប់ព័ត៌មានបន្ថែម មជ្ឈមណ្ឌលផ្ដល់ព័ត៌មានរបស់នាយកដ្ឋានសុខភាពសាធារណៈ មានបម្រើសេវាកម្មជូនចាប់ពីម៉ោង 8 ព្រឹក ដល់ម៉ោង 8 យប់ ប្រាំពីរថ្ងៃក្នុងមួយសប្ដាហ៍ តាមរយៈលេខ **1-833-540-0473**។